បោះពុម្ពនៅរោងពុម្ព នីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៧ លេខ ១៧-១៨ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសម្រេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្ដាហ៍

ពុទ្ធសាសនបណ្ឌិត្យ

[illegible]

* * *

[illegible]

# ប្រតិទិន

[illegible]

[illegible]

[illegible]

[illegible]

ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ៨-៥-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/៩៥ តែងតាំងឯកឧត្តម **មុំ សុន្ធា** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា | ៧៧៦ |
| ៩-៥-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/៩៦ តែងតាំងឯកឧត្តម **ទុំ សុខុម** ជាអគ្គលេខាធិការ នៃគណៈកម្មាធិការរៀបចំការបោះឆ្នោត | ៧៧៧ |
| ១១-៥-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/៩៧ បង្កើតគ្រឹះស្ថានសាធារណៈមួយដែលមានឧបនិស្ស័យវប្បធម៌ និង វិទ្យាសាស្ត្រមានឈ្មោះថា " រាជបណ្ឌិតសភា " | ៧៧៧ |
| ១១-៥-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/៩៨ តែងតាំងលោក **ឃុន សេដ្ឋា** ជាឧកញ៉ា | ៧៨៥ |
| ១២-៥-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/៩៩ តែងតាំងឯកឧត្តម **ម៉ៅ ផុន** ឧបការីផ្ទាល់ប្រធានរដ្ឋសភា | ៧៨៥ |
| ១៥-៥-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០០ តែងតាំងឯកឧត្តម **ឡៅ សារិន** ជាទីប្រឹក្សាផ្ទាល់របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា | ៧៨៥ |


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ៥-៥-១៩៩៩ | -អនុក្រឹត្យលេខ ៣៩ អនក្រ.បក ស្តីពីការផ្ទេរឥណទាន | ៧៨[illegible] |
| ៧-៥-១៩៩៩ | -អនុក្រឹត្យលេខ ៤០ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិ និងជួយជនចាស់ជរា | ៧៨[illegible] |
| ១២-៥-១៩៩៩ | -អនុក្រឹត្យលេខ ៤១ អនក្រ.បក ស្តីពីការបង្កើតក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ | ៧៨៩ |
| ១២-៥-១៩៩៩ | -អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ | ៧៩៣ |
| ១២-៥-១៩៩៩ | -អនុក្រឹត្យលេខ ៤៣ អនក្រ.បក ស្តីពីការបង្កើតក្រុមប្រឹក្សារំសាយកងប្រដាប់អាវុធ | ៧៩៤ |

០១-៥-១៩៩៩ -អនុក្រឹត្យលេខ ១៣៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៩៦

៧-៥-១៩៩៩ -អនុក្រឹត្យលេខ ១៣៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩៧

៧-៥-១៩៩៩ -អនុក្រឹត្យលេខ ១៣៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៧៩៧

៧-៥-១៩៩៩ -អនុក្រឹត្យលេខ ១៣៦ អនក្រ.តត ស្តីពីការតែងតាំងអភិបាលរង ខេត្ត ក្រុង ៧៩៨

១០-៥-១៩៩៩ -អនុក្រឹត្យលេខ ១៣៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៩៩

១០-៥-១៩៩៩ -អនុក្រឹត្យលេខ ១៣៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨០០

១០-៥-១៩៩៩ -អនុក្រឹត្យលេខ ១៣៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨០០

១១-៥-១៩៩៩ -អនុក្រឹត្យលេខ ១៤០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨០១

១១-៥-១៩៩៩ -អនុក្រឹត្យលេខ ១៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨០២

១១-៥-១៩៩៩ -អនុក្រឹត្យលេខ ១៤២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨០៣

១៣-៥-១៩៩៩ -អនុក្រឹត្យលេខ ១៤៣ អនក្រ.តត ស្តីពីការជូនមេដាយគុណូបការ ៨០៤

១៣-៥-១៩៩៩ -អនុក្រឹត្យលេខ ១៤៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨០៤

១៣-៥-១៩៩៩ -អនុក្រឹត្យលេខ ១៤៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨០៥


## ២-សេចក្តីសំរេច


៥-៥-១៩៩៩ -សេចក្តីសំរេចលេខ ៥១ សសរ ស្តីពីការបង្កើតគណៈកម្មការ ដើម្បីដោះស្រាយលើដីចំនួន ៣៩១ កំណាត់ស្មើនឹង ១.៥៣៧,៥២៩ម² ដែលរដ្ឋការភាពខេត្តកណ្តាលបានសំរេចអោយលក់ឡាយឡុង ៨០៦


## ៣-សេចក្តីប្រកាស


១០-៥-១៩៩៩ -សេចក្តីប្រកាសលេខ ០២ ប្រក ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុង វិស័យជលផល ៨០៩


## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ប្រកាស


៧-៥-១៩៩៩ -ប្រកាសលេខ ៣៦២ ប្រក.សហវ.ពជ ស្តីពីការបង្កើតផ្នែកគ្រប់គ្រង និងប្រមូលពន្ធតាមរបបពិត ៨១០

## ២-នីតិការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ប្រកាស


៦-៥-១៩៩៩ -ប្រកាសលេខ ៤៥០ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ស្កាយស្ការ ហ្វូត វែរ តំណាងដោយលោកស្រី LIAO YUEH MEI សញ្ជាតិ ចិន ( តៃវ៉ាន់ ) បង្កើតរោងចក្រផលិតស្បែកជើងនាំចេញ ៤១១

១៥-៥-១៩៩៩ -ប្រកាសលេខ ៥៧៦ ស្តីពី ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ខេមបូឌា កណ្ដុក ព្រីនស៍ មេនូហ្វេកឈ័រីង តំណាងដោយលោកស្រី CHENG WU[illegible] SEUNG សញ្ជាតិចិន បង្កើតរោងចក្របោះពុម្ពលើសំលៀកបំពាក់នាំចេញ ៤១២

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/៩៥

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីការវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មិនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើរបស់ប្រធានព្រឹទ្ធសភា ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៩

**ត្រាស់បង្គាប់**

**មាត្រា ១ .**_ តែងតាំង ឯកឧត្តម **ម៉ុក យុទ្ធា** ជាទីប្រឹក្សាផ្ទាល់របស់ សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកខាងសេដ្ឋកិច្ច វិនិយោគ និងជំនួយមនុស្សធម៌មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២ .**_ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/៩៦

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ .**_ តែងតាំង ឯកឧត្តម អ៊ឹម សូស្តី ជាអគ្គលេខាធិការ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានឋានៈ និងបុព្វសិទ្ធិស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២ .**_ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣ .**_ ព្រះរាជក្រឹត្យនេះចូលធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩**

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/៩៧

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**ជំពូកទី ១**

**បទបញ្ញត្តិទូទៅ**

**មាត្រា ១ ._** បង្កើតគ្រឹះស្ថានសាធារណៈមួយ ដែលមានឧបនិស្ស័យវប្បធម៌ និងវិទ្យាសាស្ត្រ មានឈ្មោះថា "**រាជបណ្ឌិត្យសភា** " ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

**មាត្រា ២ ._** រាជបណ្ឌិត្យសភាគឺជាគ្រឹះស្ថានសាធារណៈ មានទីតិបុគ្គលភាព និងមានស្វ័យភាពខាងការគ្រប់គ្រង និងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលនៃ ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៣ ._** រាជបណ្ឌិត្យសភាមានបេសកកម្មលើកទឹកចិត្ត ដឹកនាំ គ្រប់គ្រង និង ពង្រីកការស្រាវជ្រាវគ្រប់មុខជំនាញនៅក្នុងប្រទេស និងស្ថាបនាទំនាក់ទំនងសហប្រតិបត្តិការផ្នែកស្រាវជ្រាវជាមួយអង្គការជាតិ និងអន្តរជាតិ ដែលមានគោលបំណងដូចគ្នា ។

**ជំពូកទី ២**

**សមាជិក និង អ្នកឆ្លើយឆ្លង**

**មាត្រា ៤ ._** រាជបណ្ឌិត្យសភាមានសមាជិក ៣ ប្រភេទ :

**១-សមាជិកពេញសិទ្ធិ** ( Membre titulaire ) ត្រូវជ្រើសរើសដោយការបោះឆ្នោតសំងាត់ ក្នុងចំណោមសមាជិកបំរុង នៃរាជបណ្ឌិត្យសភាដែលកំពុងបំពេញភារកិច្ច ។ សមាជិកពេញសិទ្ធិអាចមាន ចំនួនពី ៥០ ទៅ ៧០ នាក់ ។

សំរាប់អាណត្តិ ៥ ឆ្នាំ ដំបូង សមាជិកពេញសិទ្ធិចំនួន ៥០ នាក់ នឹងត្រូវតែងតាំងដោយអនុក្រឹត្យពីនាយករដ្ឋមន្ត្រី ។

**២-សមាជិកបំរុង** ( Membre postulant ) ត្រូវជ្រើសរើសដោយការបោះឆ្នោតសំងាត់របស់សមាជិកពេញសិទ្ធិ ពីក្នុងចំណោមអ្នកមានសញ្ញាប័ត្របណ្ឌិត ដែលបានដាក់ពាក្យសុំចូល ។

**៣-សមាជិកសមាគមិក** (Membre associé) ត្រូវបានជ្រើសរើសដោយការបោះឆ្នោតដោយការបោះឆ្នោតសំងាត់របស់សមាជិកពេញសិទ្ធិ ពីក្នុងចំណោមជនបរទេសដែលរស់នៅក្នុង ឬក្រៅប្រទេសកម្ពុជា ហើយដែលបានជួយឧបត្ថម្ភចំពោះភាពរីកចំរើនវប្បធម៌ និងវិទ្យាសាស្ត្រ ជាគុណប្រយោជន៍ដល់ប្រទេសកម្ពុជា ។

មាត្រា ៥ ._ រាជបណ្ឌិតសភាមានអ្នកឆ្លើយឆ្លង២ប្រភេទ ៖

**១-អ្នកឆ្លើយឆ្លងជាតិ** ជាជនជាតិខ្មែររស់នៅក្នុង និងក្រៅប្រទេស ដែលស្ម័គ្រចិត្តរក្សាទំនាក់ទំនងជានិច្ចកាល ជាមួយរាជបណ្ឌិតសភា ។

**២-អ្នកឆ្លើយឆ្លងអន្តរជាតិ** ជាបណ្ឌិតជនមានសញ្ជាតិបរទេស រស់នៅក្នុងនិងក្រៅប្រទេសកម្ពុជា ដែលស្ម័គ្រចិត្តរក្សាទំនាក់ទំនងជានិច្ចកាល ជាមួយរាជបណ្ឌិតសភា ។

មាត្រា ៦ ._ លក្ខណៈជាសមាជិកពេញសិទ្ធិ ជាសមាជិកបំរុង ឬជាអ្នកឆ្លើយឆ្លង ត្រូវរលាយបាត់ទៅវិញ ដោយមរណភាព ដោយការសុំលាលែង ឬដោយការលុបឈ្មោះចេញពីបញ្ជី ។

## ជំពូកទី ៣

## អង្គការដឹកនាំ ៖

## ក្រុមប្រឹក្សាភិបាល និង គណៈកម្មាធិការប្រតិបត្តិ

### ក- ក្រុមប្រឹក្សាភិបាល

មាត្រា ៧ ._ រាជបណ្ឌិតសភាស្ថិតនៅក្រោមការដឹកនាំនៃក្រុមប្រឹក្សាភិបាលមួយដែលមាននាយករដ្ឋមន្ត្រីជាប្រធានកិត្តិយស និងមានសមាសភាព ដូចខាងក្រោមនេះ ៖

| | |
|---|---|
| - ប្រធានរាជបណ្ឌិតសភា | ប្រធាន |
| - តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| - សមាជិកគណៈកម្មាធិការប្រតិបត្តិ នៃរាជបណ្ឌិតសភា | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យនានា | សមាជិក |
| - អគ្គលេខាធិការ នៃរាជបណ្ឌិតសភា | សមាជិកកត់ត្រា |

មាត្រា ៨ ._ ប្រធានក្រុមប្រឹក្សាភិបាលជាអ្នកកោះប្រជុំក្រុមប្រឹក្សាភិបាល ។ ការប្រជុំចាត់ទុកជាបានការលុះត្រាតែមានសមាជិកចំនួន ៥នាក់យ៉ាងតិច ដោយមានប្រធាន ឬ អនុប្រធានចូលរួម ។

សេចក្ដីសំរេចចិត្តត្រូវយកតាមសំលេងភាគច្រើន បើមានសំលេងស្មើគ្នា សំលេងប្រធានជាសំលេងកំណត់ ។ សមាជិកទាំងអស់ដែលបានមកប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ នៃការប្រជុំ ។

មាត្រា ៩ ._ ក្រុមប្រឹក្សាភិបាលមានភារកិច្ច ៖

១-អនុម័តលើបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈ នៃបុគ្គលិករាជបណ្ឌិតសភា ។

២-សំរេចបង្កើតមន្ទីរពិសោធន៍ កន្លែងអនុវត្តការពិសោធន៍ មជ្ឈមណ្ឌលស្រាវជ្រាវផ្សេងៗ ដើម្បីអោយរាជបណ្ឌិតសភាអនុវត្តការងារបានសមស្រប ។

៣-កំណត់ការបែងចែកចំនួនកន្លែងបុគ្គលិកក្នុងវិទ្យាស្ថានផ្សេងៗ និងសំរេចលើការជ្រើសរើសសមាជិកនៃរាជបណ្ឌិតសភា ។

៤-អនុម័តលើតារាងថវិកានៃរាជបណ្ឌិតសភា និងកម្មវិធីប្រចាំឆ្នាំ ឬផែនការយូរអង្វែងរបស់រាជបណ្ឌិតសភា ។

៥-អនុម័តលើគណនី និងលើតុល្យការនៅចុងការិយបរិច្ឆេទ ។

៦-អនុម័តលើកិច្ចសន្យា និងកិច្ចព្រមព្រៀងផ្សេងៗ ។

៧-ទទួលអំណោយ និងប្រាក់ឧបត្ថម្ភផ្សេងៗ ។

៨-បង្កើត និងជូនរង្វាន់ដល់ រូបវន្តបុគ្គល និងនីតិបុគ្គល ដែលបានបង្កើតសមិទ្ធិស្របនឹងគោលបំណងរបស់រាជបណ្ឌិតសភា ។

៩-ត្រួតពិនិត្យរបាយការណ៍ របស់គណៈកម្មាធិការប្រតិបត្តិ ។

**ខ-គណៈកម្មាធិការប្រតិបត្តិ**

មាត្រា ១០ ._ រាជបណ្ឌិតសភាត្រូវគ្រប់គ្រងផ្ទាល់ដោយគណៈកម្មាធិការប្រតិបត្តិមួយដែលមានបណ្ឌិត ៤ នាក់ គឺ :

- ប្រធាន
- សមាជិក ១ នាក់ : ទទួលបន្ទុក ២ វិទ្យាស្ថាន
- សមាជិក ១ នាក់ : ទទួលបន្ទុក ២ វិទ្យាស្ថាន
- សមាជិក ១ នាក់ : ទទួលបន្ទុក ជាអគ្គលេខាធិការ

មាត្រា ១១ ._ ប្រធានគណៈកម្មាធិការប្រតិបត្តិការមានឋានៈស្មើរដ្ឋលេខាធិការ សមាជិកទាំង៣រូបមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ១២ ._ ប្រធាន និងសមាជិក នៃគណៈកម្មាធិការប្រតិបត្តិត្រូវជ្រើសរើសដោយសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិតសភា តាមរយៈការបោះឆ្នោតសំងាត់ សំរាប់អាណត្តិ ៥ ឆ្នាំ ។

ក្នុងអាណត្តិ ៥ ឆ្នាំ ដំបូងនេះ ក្រៅពីប្រធាន សមាជិកទាំង ៣រូប ត្រូវជ្រើសរើសពីក្នុងចំណោមសមាជិកពេញសិទ្ធិ និងដោយសមាជិកពេញសិទ្ធិ តាមរយៈការបោះឆ្នោតសំងាត់ ។

មាត្រា ១៣ ._ ប្រធាននៃរាជបណ្ឌិតសភាដឹកនាំការប្រជុំ ដោយរក្សារបៀបរៀបរយនៃការប្រជុំ និងអាចអញ្ជើញឥស្សរជនពីខាងក្រៅ មកចូលរួម ។

មាត្រា ១៤ ._ ក្នុងករណីដែលប្រធានមានធុរកិច្ច សមាជិកមួយរូបនៃគណៈកម្មាធិការប្រតិបត្តិ នឹងត្រូវចាត់តាំងអោយដឹកនាំការប្រជុំជំនួស ។

## ជំពូកទី ៤

## មហាសន្និបាត

មាត្រា ១៥ ._ មហាសន្និបាតត្រូវធ្វើតែក្នុងក្របខ័ណ្ឌសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិតសភា ។ សមាជិកផ្សេងៗទៀតអាចចូលស្តាប់បាន ប៉ុន្តែពុំមានសំលេងពិភាក្សាឡើយ ។

មាត្រា ១៦ ._ មហាសន្និបាតសាមញ្ញប្រចាំឆ្នាំ ត្រូវរៀបចំធ្វើនៅដើមឆ្នាំ ដើម្បី :

១-ស្តាប់របាយការណ៍របស់ប្រធាន ស្តីពីសកម្មភាពនៃរាជបណ្ឌិតសភា

២-ស្តាប់របាយការណ៍របស់ស្នងការគណនី ស្តីពីការស្ថានភាពហិរញ្ញវត្ថុ នៃរាជបណ្ឌិតសភា

៣-ពិភាក្សាលើបញ្ហាដែលមានចែងក្នុងរបៀបវារៈ ។

**មាត្រា ១៧ .**_ មហាសន្និបាតវិសាមញ្ញ ត្រូវកោះប្រជុំ ៥ ឆ្នាំ ម្តង ដើម្បីជ្រើសរើសប្រធាន និងសមាជិក នៃគណៈកម្មាធិការប្រតិបត្តិ សំរាប់អាណត្តិថ្មី ។

**មាត្រា ១៨ .**_ មហាសន្និបាត នឹងយកជាបានការ លុះត្រាតែមានសមាជិកពេញសិទ្ធិយ៉ាងតិចត្រឹមពាក់កណ្តាលមកប្រជុំ ។ សេចក្តីសំរេចត្រូវយកតាមសំលេងភាគច្រើន ។ បើមានសំលេងស្មើគ្នា សម្លេងរបស់ប្រធានទុកជាបានការ ។

**មាត្រា ១៩ .**_ បើមហាសន្និបាតមិនគ្រប់កូរ៉ុម មហាសន្និបាតថ្មីមួយទៀតត្រូវកោះប្រជុំ ១៥ ថ្ងៃ ក្រោយពីថ្ងៃប្រជុំមហាសន្និបាតមុន ។ មហាសន្និបាតទី២នេះអាចយកជាបានការ ទោះបីមានសមាជិកពេញសិទ្ធិប៉ុន្មាននាក់ចូលរួមក៏ដោយ ។

## ជំពូកទី ៥

## ស្ថាប័នឧបសម្ព័ន្ធ នៃ រាជបណ្ឌិតសភា

**មាត្រា ២០ .**_ រាជបណ្ឌិតសភាមានវិទ្យាស្ថានឧបសម្ព័ន្ធចំនួន ៤ ដូចខាងក្រោមនេះ :

**១-វិទ្យាស្ថាន វប្បធម៌ និង វិចិត្រសិល្បៈ**

ក-ផ្នែកវប្បធម៌ប្រជាប្រិយ និង អរិយធម៌

ខ-ផ្នែកសិល្បៈសូនរូប និងតស្សរិយយស

គ-ផ្នែកស្ថាបត្យកម្ម

ឃ-ផ្នែកបុរាណវិទ្យា

ង-ផ្នែកសិល្បៈ

**២-វិទ្យាស្ថាន មនុស្សសាស្ត្រ និង វិទ្យាសាស្ត្រសង្គម**

ក-ផ្នែកភាសា និង អក្សរសាស្ត្រ

ខ-ផ្នែកធម្មសាស្ត្រ ចរិយាសាស្ត្រ និងសាសនា

គ-ផ្នែកនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

ឃ-ផ្នែកពាណិជ្ជសាស្ត្រ និង ការគ្រប់គ្រង

ង-ផ្នែកប្រវត្តិវិទ្យា និង វិទ្យាសាស្ត្រនយោបាយ

ច-ផ្នែកភូមិវិទ្យា និង នគរូបនីយកម្ម

ឆ-ផ្នែកទស្សនវិទ្យា និង សង្គមវិទ្យា

ជ-ផ្នែកនរវិទ្យា និង ជាតិពន្ធុវិទ្យា

ឈ-ផ្នែកចិត្តវិទ្យា គរុកោសល្យ និង វិទ្យាសាស្ត្រអប់រំ

៣-វិទ្យាស្ថាន ជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម

ក-ផ្នែក បរិស្ថានធម្មជាតិ និង ជីវវិទ្យា

ខ-ផ្នែក វេជ្ជសាស្ត្រ ទន្តសាស្ត្រ និង ឱសថសាស្ត្រ

គ-ផ្នែក កសិកម្ម

៤-វិទ្យាស្ថាន វិទ្យាសាស្ត្រ និង បច្ចេកទេស

ក-ផ្នែក គណិតវិទ្យា និង ស្ថិតិ

ខ-ផ្នែក គីមី និង ចំណីអាហារ

គ-ផ្នែក រូបវិទ្យា និង ថាមពល

ឃ-ផ្នែក បច្ចេកវិទ្យា

ង-ផ្នែក ពត៌មានវិទ្យា និង ទូរគមនាគមន៍

មាត្រា ២១ ._ វិទ្យាស្ថាននីមួយៗស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីចាត់ការមួយដែលមាន :

- ប្រធានវិទ្យាស្ថាន : ១ នាក់
- អនុប្រធានវិទ្យាស្ថាន : ១ នាក់
- លេខាធិការអចិន្ត្រៃយ៍ : ១ នាក់

មាត្រា ២២ ._ ផ្នែកនីមួយៗត្រូវគ្រប់គ្រងដោយប្រធានផ្នែក ១ នាក់ ដែលត្រូវតែងតាំងដោយប្រធាន នៃវិទ្យាស្ថាន ។

## ជំពូកទី ៦

## អង្គការហិរញ្ញវត្ថុ

មាត្រា ២៣ ._ កាលបរិច្ឆេទហិរញ្ញវត្ថុ នៃរាជបណ្ឌិតសភាគឺ ពីថ្ងៃទី ១ មករា ទៅទល់នឹងថ្ងៃទី៣១ ធ្នូ ។ ក្រុមប្រឹក្សាភិបាលពិនិត្យសំរេចលើគំរោងថវិកាក្នុងរវាង ២ ខែមុនចាប់ផ្តើម ។ ថវិកាត្រូវគ្រោងទុកនូវប្រាក់ចំណូល និងប្រាក់ចំណាយ សំរាប់ចាត់ចែងក្នុងរាជបណ្ឌិតសភា និងក្នុងការធានានូវដំណើរប្រព្រឹត្តិទៅ នៃផ្នែកនានានៅក្រោមឱវាទ ។

មាត្រា ២៤ ._ ប្រាក់ចំណូលនៃរាជបណ្ឌិតសភាមាន :

- ជំនួយពីថវិកាជាតិ
- ប្រាក់ចំណូលបានមកពីការលក់ស្នាដៃបោះពុម្ពផ្សាយ និងកិច្ចការស្រាវជ្រាវផ្សេងៗ
- អំណោយ និង ជំនួយឧបត្ថម្ភពីអង្គការជាតិ និង អន្តរជាតិ ។

មាត្រា ២៥ ._ អគ្គលេខាធិការ ដែលបំពេញមុខងារជាអ្នកចាត់ចែងការចំណាយ ត្រូវធ្វើការបញ្ជាក់លើលិខិតចំណូល និងចំណាយ ហើយត្រូវទទួលខុសត្រូវក្នុងការរក្សាប្រាក់ និងរបៀបកាន់បញ្ជីផ្សេងៗ ។

## ជំពូកទី ៧

## ការត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ២៦ .**_ ការត្រួតពិនិត្យហិរញ្ញវត្ថុលើរាជបណ្ឌិតសភាត្រូវធ្វើដោយស្នងការគណនេយ្យពីរនាក់ មួយនាក់ត្រូវតែងតាំងដោយនាយករដ្ឋមន្ត្រី និងមួយនាក់ទៀតត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ស្នងការគណនេយ្យត្រូវបានទទួលប្រាក់បំណាច់ តាមការកំណត់ពីក្រុមប្រឹក្សាភិបាល និងបានប្រាក់ឧបត្ថម្ភសំរាប់ការធ្វើដំណើរ និង ស្នាក់នៅ ។

**មាត្រា ២៧ .**_ ស្នងការគណនេយ្យត្រូវបញ្ជូនជារៀងរាល់ឆ្នាំ នូវរបាយការណ៍ទៅនាយករដ្ឋមន្ត្រី និងទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីលទ្ធផលនៃការត្រួតពិនិត្យរបស់ខ្លួន ។

## ជំពូកទី ៨

## បទបញ្ញត្តិផ្សេងៗ

**មាត្រា ២៨ .**_ ក្នុងពេលដំណើរការដំបូង រាជបណ្ឌិតសភាត្រូវស្ថិតនៅក្រោមបញ្ជាជាបណ្ដោះអាសន្នពីនាយករដ្ឋមន្ត្រី ។

**មាត្រា ២៩ .**_ បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣០ .**_ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣១ .**_ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គរ ថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

# ព្រះរាជក្រឹត្យ

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/៩៨

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

តែងតាំង

លោក ហុង សេដ្ឋា

ជា

ឧកញ៉ា

ធ្វើនៅសៀមរាប អង្គារ៍ថ្ងៃទី១១ ខែឧសភា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/៩៩

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ញត្តិក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- យោងតាមសំណើ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

**ត្រាស់បង្គាប់**

**មាត្រា ១ .**_ តែងតាំង ឯកឧត្តម **ម៉ា ជន** ឧបការី ផ្ទាល់ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ .**_ អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា រាជរដ្ឋាភិបាល និងសាមីខ្លួនត្រូវអនុវត្ត អោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .**_ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គរ ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០០**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ញាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណើ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃ ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

**ត្រាស់បង្គាប់**

**មាត្រា ១ .**_ តែងតាំង ឯកឧត្តម **ញៀម សារិន** ជាទីប្រឹក្សាផ្ទាល់របស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២ .**_ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្ត អោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គរ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៣៩ អនក្រ.បក

### ស្តីពីការផ្ទេរឥណទាន

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នរ/រកម/០១/៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូល និង ផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ .**_ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២.០០០ លានរៀល (ពីរពាន់លានរៀល) ពីជំពូក ៥០ ( ចំណាយផ្សេងៗ ) ចំនួន ៧៨០ លានរៀល ( ប្រាំពីររយប៉ែតសិបលានរៀល ) និង ពីជំពូក ៥១ ( ចំណាយឥតគ្រោងទុក ) ចំនួន ១.២២០ លានរៀល ( មួយពាន់ពីររយម្ភៃលានរៀល ) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ក្រសួងអប់រំ យុវជន និង កីឡា ផ្នែក អប់រំ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

**មាត្រា ២ .**_ ឥណទានថវិកាក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់បោះពុម្ពសៀវភៅសិក្សាចំណេះទូទៅថ្នាក់ទី ១០ សំរាប់សិស្ស និងគ្រូ ប្រចាំឆ្នាំ ១៩៩៩ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែឧសភា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤០ អនក្រ.បក
## ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិ និង ជួយជនចាស់ជរា

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិ និង ជួយជនចាស់ជរា
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៨

- ពីរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា
- យោងសេចក្តីសំរេចរបស់គណៈកម្មាធិការអភិវឌ្ឍន៍សង្គម នៃអង្គការសហប្រជាជាតិ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ១៩៩៧

**សំរេច**

មាត្រា ១ ._ បង្កើតគណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិ និង ជួយជនចាស់ជរា ដែលមានសមាសភាពដូចតទៅ ៖

១-សម្តេច នាយករដ្ឋមន្ត្រី ជាប្រធានកិត្តិយស

២-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ជាប្រធាន

៣-រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ជាអនុប្រធាន

៤-អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ជាអនុប្រធាន

៥-អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ជាអនុប្រធាន

៦-តំណាងក្រសួងមហាផ្ទៃ ជាសមាជិក

៧-តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ជាសមាជិក

៨-តំណាងក្រសួងធម្មការ និងសាសនា ជាសមាជិក

៩-តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិក

១០-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

១១-តំណាងក្រសួងពត៌មាន ជាសមាជិក

១២-តំណាងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ជាសមាជិក

១៣-តំណាងគណៈកម្មការសមាគមជាតិកាកបាទក្រហមកម្ពុជា ជាសមាជិក

មាត្រា ២ ._ គណៈកម្មាធិការនេះអាចមានទីប្រឹក្សាបច្ចេកទេសស្ម័គ្រចិត្តតាមការចាំបាច់ ដោយស្នើពីសមាគមមនុស្សចាស់នានានៅកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលក្នុង និងក្រៅប្រទេស និងអង្គការអន្តរជាតិ ។

មាត្រា ៣ ._ គណៈកម្មាធិការនេះភារកិច្ចដូចតទៅ ៖

១-រៀបចំគោលនយោបាយជាតិ ដើម្បីលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ ពិសេសជនចាស់ជរាអោយប្រសើរឡើង ។

២-រៀបចំទិវាមនុស្សចាស់អន្តរជាតិ ជារៀងរាល់ឆ្នាំដោយកំណត់យកថ្ងៃទី០១ ខែតុលា ។

៣-សហការសម្របសម្រួលជាមួយស្ថាប័នជាតិ អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងនិងក្រៅប្រទេស និងសប្បុរសជននានាដើម្បីចូលរួមឧបត្ថម្ភគាំទ្រដល់ជនចាស់ជរានៅកម្ពុជា ។

៤-លើកតំរោងថវិកាជាតិ ដែលស្ថិតក្នុងបន្ទុកផែនការថវិកាចំណាយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទាសំរាប់រៀបចំទិវាមនុស្សចាស់អន្តរជាតិជារៀងរាល់ឆ្នាំនិង សំរាប់បំរើកម្មវិធីសេវាកម្មផ្សេងៗ ដល់មនុស្សចាស់ ។

៥-បង្កើតអនុគណៈកម្មាធិការរៀបចំទិវាមនុស្សចាស់អន្តរជាតិ និងជួយជនចាស់ជរាតាមខេត្ត-ក្រុង តាមការចាំបាច់ ។

**មាត្រា ៤ ._** សមាជិកនៃគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន ។

**មាត្រា ៥ ._** គណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិ និងជួយជនចាស់ជរាត្រូវកំណត់តួនាទីភារកិច្ច នៃតំណាងក្រសួង ស្ថាប័ន ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះអាចបង្កើតលេខាធិការដ្ឋាន អចិន្ត្រៃយ៍មួយ ប្រចាំនៅក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទាដោយ ប្រើក្របខ័ណ្ឌមានស្រាប់ ដើម្បីជំនួយការក្នុងកិច្ចសហការសម្របសម្រួលដោះស្រាយរាល់ការងារ ដែលពាក់ព័ន្ធ បញ្ហាជនចាស់ជរាកម្ពុជា និងដំណើរការរៀបចំទិវាមនុស្សចាស់អន្តរជាតិ ។ តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំទិវាមនុស្ស ចាស់អន្តរជាតិ និងជួយជនចាស់ជរា ។ គណៈកម្មាធិការជាតិនេះត្រូវប្រើត្រាក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដើម្បីដំណើរការ ។

**មាត្រា ៦ ._** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងពាក់ព័ន្ធ និងគ្រប់អង្គការជាតិដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤១ អនក្រ.បក

## ស្តីពីការបង្កើតក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

***

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- តាមសំណើរបស់ប្រធាន ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

**សំរេច**

**ជំពូក ១**

**ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ**

មាត្រា ១ .- ត្រូវបានបង្កើតក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ដែលមានស្វ័យភាពរដ្ឋបាល ។ ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ មានបេសកកម្មអនុលោមទៅតាមការតំរង់ទិស និងស្ថិតនៅក្រោមការត្រួតពិនិត្យមើលរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងការផ្តួចផ្តើម និង ជំរុញការដោះស្រាយបញ្ហារំសាយកងកំលាំងប្រដាប់អាវុធ និង ព្រមទាំងដើរតួជានិយតករ និង ជាកំលាំងជំរុញដោយមានការទទួលខុសត្រូវ និង មានការយកចិត្តទុកដាក់ខ្ពស់លើលទ្ធផលជាក់ស្តែង ។

មាត្រា ២ .- ដើម្បីប្រតិបត្តិបេសកកម្មដូចមានចែងក្នុងមាត្រា១ ខាងលើ ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ បំពេញមុខងារដូចតទៅ :

១-ផ្តួចផ្តើម និង លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវយុទ្ធសាស្ត្រ និង កម្មវិធីការងារសំរាប់ធ្វើអោយសំរេចគោលដៅទាំងអស់ ក្នុងក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ។

២-អនុវត្តសេចក្តីណែនាំទាំងអស់ដែលទទួលបានពីឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងការដាក់អោយដំណើរការយុទ្ធសាស្ត្រ និង កម្មវិធីរំសាយកងកំលាំងប្រដាប់អាវុធ ។

៣-លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវគ្រប់សេចក្តីព្រាងអត្ថបទ ឬ គ្រប់វិធានការណ៍ចាំបាច់ក្នុងការដាក់អោយដំណើរការ ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ។

៤-រៀបចំគោលនយោបាយ និង កសាងផែនការការងារអោយបានច្បាស់លាស់ ជុំវិញការងាររំសាយកងកំលាំងប្រដាប់អាវុធ ។ -

៥-ធ្វើទំនាក់ទំនងជាមួយអាជ្ញាធរ ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និង អន្តរជាតិនៃបណ្តាប្រទេសជាមិត្ត និង មួយផ្នែកជាមួយឯកជនផ្សេងៗ ជាពិសេសយកចិត្តទុកដាក់ដល់ការគេណ្ឌធនធានផ្ទាល់របស់រដ្ឋ និង ជំនួយអន្តរជាតិចាំបាច់សំរាប់យកមកប្រើប្រាស់ក្នុងការដាក់អោយដំណើរការ ការរំសាយកងកំលាំងប្រដាប់អាវុធ ។

៦-ចេញសេចក្តីសំរេច និង សេចក្តីណែនាំចាំបាច់ក្នុងការដាក់អោយដំណើរការការរំសាយកងកំលាំងប្រដាប់អាវុធ ក្នុងព្រំដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ៣ .-** ក្រុមប្រឹក្សាស៊ើបអង្កេតកងកម្លាំងប្រដាប់អាវុធ មានសមាសភាព ដូចតទៅ ៖

| | |
|---|---|
| -ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| -រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| -អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| -រដ្ឋលេខាធិការមួយរូប នៃក្រសួងមហាផ្ទៃ | សមាជិក |
| -រដ្ឋលេខាធិការមួយរូប នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| -រដ្ឋលេខាធិការមួយរូប នៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| -រដ្ឋលេខាធិការមួយរូប នៃក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | សមាជិក |
| -រដ្ឋលេខាធិការមួយរូប នៃក្រសួងកិច្ចការនារី និង អតីតយុទ្ធជន | សមាជិក |
| -រដ្ឋលេខាធិការមួយរូប នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| -ទីប្រឹក្សា សម្តេច នាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារយោធា | សមាជិក |
| -រដ្ឋលេខាធិការមួយរូប នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ | សមាជិក |
| -អនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| -នាយសេនាធិការចំរុះ នៃអគ្គបញ្ជាការដ្ឋាន | សមាជិក |

**មាត្រា ៤ .-** ប្រធានក្រុមប្រឹក្សាស៊ើបអង្កេតកងកម្លាំងប្រដាប់អាវុធ ត្រូវរ៉ាប់រងបំពេញបន្ទុក នៃមុខការទាំងឡាយរបស់ក្រុមប្រឹក្សាស៊ើបអង្កេតកងកម្លាំងប្រដាប់អាវុធ ដូចមានចែងក្នុងមាត្រា ២ ខាងលើ និង យកចិត្តទុកដាក់ធ្វើអោយដំណើរការ នៃការងារស៊ើបអង្កេតកងកម្លាំងប្រដាប់អាវុធប្រព្រឹត្តទៅបានល្អជាទូទៅ ។

.ប្រធានក្រុមប្រឹក្សាស៊ើបអង្កេតកងកម្លាំងប្រដាប់អាវុធ ជាអ្នកកំណត់របៀបវារៈ នៃការប្រជុំនានារបស់ក្រុមប្រឹក្សាស៊ើបអង្កេតកងកម្លាំងប្រដាប់អាវុធ ដឹកនាំការពិភាក្សា និង ចេញសេចក្តីសំរេចទាំងអស់ ។

.ប្រធានក្រុមប្រឹក្សាស៊ើបអង្កេតកងកម្លាំងប្រដាប់អាវុធ អាចអញ្ជើញគ្រប់សមាជិករាជរដ្ឋាភិបាល ឬឥស្សរជន ដែលមានគុណសម្បត្តិគ្រប់គ្រាន់មកចូលរួមក្នុងការប្រជុំនានា ។

.ប្រធានក្រុមប្រឹក្សាស៊ើបអង្កេតកងកម្លាំងប្រដាប់អាវុធ មានសិទ្ធិក្នុងការចុះហត្ថលេខាជាទ្វេភាគី និងជាពហុភាគីលើគ្រប់អនុស្សរណៈ នៃហិរញ្ញប្បទាន និង គ្រប់កិច្ចសន្យា ឬ អត្ថបទគតិយុត្ត ដែលទាក់ទងទៅនឹងការងារស៊ើបអង្កេតកងកម្លាំងប្រដាប់អាវុធ ដោយអនុលោមទៅតាមអត្ថបទច្បាប់ ឬបទបញ្ញត្តិពីបញ្ហានេះ ។

.ប្រធានក្រុមប្រឹក្សាស៊ើបអង្កេតកងកម្លាំងប្រដាប់អាវុធ មានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការគ្រប់គ្រងរដ្ឋបាល និង ហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាស៊ើបអង្កេតកងកម្លាំងប្រដាប់អាវុធ ។

## ជំពូក ២

## អគ្គលេខាធិការដ្ឋាន

**មាត្រា ៥ .**_ ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ មានសេវាប្រតិបត្តិការ ដែលត្រូវបានគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ។

.អគ្គលេខាធិការនៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ត្រូវបានតែងតាំងដោយអនុក្រឹត្យ។

.អគ្គលេខាធិការ អាចមានអគ្គលេខាធិការរងមួយចំនួន មានឋានៈស្មើអគ្គនាយករង ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ ។

.អគ្គលេខាធិការរ៉ាប់រងការដឹកនាំ និង ការគ្រប់គ្រងសេវាប្រតិបត្តិការនានារបស់ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ តាមរបៈប្រតិភូសិទ្ធិ និង ក្រោមការត្រួតពិនិត្យរបស់ប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ។

## ជំពូក ៣

## បុគ្គលធនធាន

**មាត្រា ៦ .**_ បុគ្គលិកនៃសេវាប្រតិបត្តិ នឹងអាចជាភ្នាក់ងាររដ្ឋ ឬ ជាភ្នាក់ងារជាប់កិច្ចសន្យា ។ លក្ខខ័ណ្ឌនៃលាភការរបស់ភ្នាក់ងារជាប់កិច្ចសន្យា និង ប្រាក់បំណាច់ពិសេសសំរាប់បើកជូនភ្នាក់ងាររដ្ឋ និង ត្រូវបានកំណត់ដោយប្រកាសរបស់ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ តាមសំណើរបស់អគ្គលេខាធិការ ។

**មាត្រា ៧ .**_ ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ មានខ្ទង់ថវិកា ដោយឡែកនៅក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ធនធានទាំងអស់របស់ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធមាន :

-ថវិកាជាតិ

-ហិរញ្ញប្បទាន បានមកពីប្រទេស ឬ អង្គការផ្តល់ជំនួយអន្តរជាតិ ។

-វិភាគទានរបស់ផ្នែកឯកជន

ប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ជាអាណាប័កប្រតិភូនៃថវិការបស់ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ។

## ជំពូក ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៨ .**_ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩ .**_ អនុក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**មាត្រា១០.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួង

សង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង និតិសម្បទា ព្រមទាំងរដ្ឋមន្ត្រីនៃបណ្តាក្រសួង និង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៤២ អនក្រ.បក**

**ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយ**

**កងកំលាំងប្រដាប់អាវុធ**

***

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- តាមសំណើរបស់ប្រធាន ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

**សំរេច**

**ជំពូក ១**

**អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ**

**មាត្រា ១ ._** ត្រូវបានបង្កើត អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ដែលមានស្វ័យភាពរដ្ឋបាល ។

**មាត្រា ២ ._** អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ សមាសភាពដូចតទៅ :

-ឯកឧត្តម **ស្វាយ ស៊ីថា** អនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី ជាអគ្គលេខាធិការ

-ឯកឧត្តម **ព្រំ សំអុល** ជាអគ្គលេខាធិការរង មានឋានៈស្មើអគ្គនាយករង

-ឯកឧត្តម **ខៀវ ឆេង** ជាអគ្គលេខាធិការរង មានឋានៈស្មើអគ្គនាយករង

## ជំពូក ២

## អវសានប្បញ្ញត្តិ

**មាត្រា ៣ ._** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ ._** អនុក្រឹត្យនេះ មានឥទ្ធិពល ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**មាត្រា ៥ ._** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីមហាផ្ទៃ រដ្ឋមន្ត្រីកសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង នីតិសម្បទា ព្រមទាំងរដ្ឋមន្ត្រីនៃបណ្តាក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤៣ អនក្រ.បក

## ស្តីពីការបង្កើតក្រុមប្រឹក្សារំសាយ

## កងកំលាំងប្រដាប់អាវុធ

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- តាមសំណើរបស់ប្រធាន ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

## សំរេច

## ជំពូក ១

## ក្រុមប្រឹក្សារំសាយកងប្រដាប់អាវុធ

**មាត្រា ១ .**_ ត្រូវបានបង្កើតក្រុមប្រឹក្សារំសាយកងប្រដាប់អាវុធ ដែលមានស្វ័យភាពរដ្ឋបាល ។ ក្រុមប្រឹក្សារំសាយកងប្រដាប់អាវុធ មានបេសកកម្មអនុលោមទៅតាមការតំរង់ទិស និង ស្ថិតនៅក្រោមការត្រួតពិនិត្យមើលរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងការផ្តួចផ្តើម និង ជំរុញការដោះស្រាយបញ្ហារំសាយកងប្រដាប់អាវុធ ព្រមទាំងដើរតួជានិយតករ និង ជាកំលាំងជំរុញដោយមានការទទួលខុសត្រូវ និង មានការយកចិត្តទុកដាក់ខ្ពស់លើលទ្ធផលជាក់ស្តែង ។

**មាត្រា ២ .**_ ក្រុមប្រឹក្សារំសាយកងប្រដាប់អាវុធ មានសមាសភាពដូចតទៅ ៖

-ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធាន

-ឯកឧត្តម ឧត្តមសេនីយ៍ឯក **មាស សុផា** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ អនុប្រធាន

-ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

-ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ សមាជិក

-ឯកឧត្តម **លី ធុច** រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

-ឯកឧត្តម **នឹម ថូត** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក

-លោកជំទាវ **យូ អយ** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន សមាជិក

-ឯកឧត្តម **ចាន់ តុងអ៊ីវ** រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ សមាជិក

-ឯកឧត្តម **នូ សាំងខន** រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ សមាជិក

-ឯកឧត្តម **ម៉ុល រឿប** ទីប្រឹក្សា សម្តេច នាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារយោធា សមាជិក

-ឯកឧត្តម **ស្វាយ ស៊ីថា** អនុរដ្ឋលេខាធិការ អមទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក-

ឯកឧត្តមឧត្តមសេនិយទោ **តួច ស៊ីផាន** នាយសេនាធិការរងចំរុះនៃអគ្គបញ្ជាការ សមាជិក

## ជំពូក ២

## អវសានប្បញ្ញត្តិ

**មាត្រា ៣ .**_ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ .**_ អនុក្រឹត្យនេះ មានគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**មាត្រា ៥ .**_ រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួង

សង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង នីតិសម្បទា ព្រមទាំងរដ្ឋមន្ត្រីនៃបណ្តាក្រសួងនិងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១៣៣ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**មាត្រា ១ ._** តែងតាំងលោក **អ៊ាង សុផល្លែត** ជា ជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជាមានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២ ._** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ១៣៤ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើ គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

### សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី OSANAI MIEKO ប្រធានអង្គការ JHP ជប៉ុន ដែលបានធ្វើអំណោយអាគារសិក្សាមួយខ្នង ជូនសាលាបឋមសិក្សាទួលអំពិល ឃុំបាគក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង មានតម្លៃជាទឹកប្រាក់ ចំនួន ២៤.៣០០ ដុល្លារអាមេរិក ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាល ខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១៣៥ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើ គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយអស្សឫទ្ធិសហមេត្រី ជូនលោកព្រឹទ្ធបាលឯក GEORGES PUISSANT បុគ្គលិកយោធាបារាំង ដែលមានស្នាដៃល្អក្នុងការបំពេញបេសកកម្មនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកស្ទួយទំនាក់ទំនងមិត្តភាព និងកិច្ចប្រតិបត្តិការយោធាបារាំង - ខ្មែរ ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១៣៦ អនក្រ.តត

## ស្តីពីការ តែងតាំងអភិបាលរង ខេត្ត-ក្រុង

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

**មាត្រា ១ ._** ត្រូវបានតែងតាំងលោក គែវ ចាន ជា អភិបាលរងទី ៣ ក្រុងប៉ៃលិន ។

**មាត្រា ២ ._** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ១៣៧ អនក្រ.គត**

**ស្ដីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសប្រើ គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

**សំរេច**

**មាត្រា ១ .** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្ដម ឧត្ដមសេនីយឯក **ហុក ឡុងឌី** អគ្គនាយកនគរបាលជាតិ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនអស់ចំនួន ៣៦.០០០ ដុល្លារអាមេរិកសំរាប់សាងសង់អាគារធ្វើការមួយខ្នងមាន ១៧ បន្ទប់ ជូនស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ ។

**មាត្រា ២ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត កំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**អនុក្រឹត្យលេខ ១៣៨ អនក្រ.តត**
**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៨៥/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើ គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **លឹម សុផាត** ប្រធានសមាគមគណៈកម្មការមន្ទីរពេទ្យ និងកុមារកំព្រា " CHOC " កម្ពុជាដែលបានជួយកសាងមណ្ឌល សុខភាពវិហារសួគ៌មួយខ្នង ព្រមទាំងបំពាក់សម្ភារៈបរិក្ខារ និងម៉ាស៊ីនភ្លើងមានតម្លៃសរុបចំនួន ២៩.០០០ ដុល្លារអាមេរិក ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងអភិបាល ខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ១៣៩ អនក្រ.តត**
**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា ១ ._** តែងតាំងលោក **លឹម ម៉េងហេង** បច្ចុប្បន្នមន្ត្រីថ្នាក់ប្រធាននាយកដ្ឋាន នៃក្រសួងពាណិជ្ជកម្មជាទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង ទទួលបន្ទុកសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និង ទេសចរណ៍ ។

**មាត្រា ២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១៤០ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការចាំបាច់នៃការងាររាជរដ្ឋាភិបាល

**សំរេច**

**មាត្រា ១ ._** ត្រូវបានតែងតាំងលោក **ហ៊ុន ហេង** ជា ជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាមានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២ ._** បទបញ្ញត្តិទាំងឡាយណាដែល មានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១៤១ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

**សំរេច**

**មាត្រា ១ ._** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកឧកញ៉ា **សោ សេរីមុន្នី** ហៅ **យ៉ាត** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចំនួន ១៣.០០០ ដុល្លារអាមេរិក សំរាប់ជួយកសាង សាលារៀន វត្តអារាម និងសង់ផ្ទះជូនប្រជាពលរដ្ឋក្រីក្រនៅក្នុងស្រុករំដួល ខេត្តស្វាយរៀង ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១៤២ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងពត៌មាន

## សំរេច

មាត្រា ១ ._ ត្រូវបានតែងតាំងលោកស្រី លឹម មុំ ជាប្រធាននាយកដ្ឋានផែនការ គណនេយ្យ និង ហិរញ្ញកិច្ច នៃក្រសួងពត៌មាន ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១៩៣ អនក្រ.តត
## ស្តីពីការជូនមេដាយសុវត្ថារា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៨ស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

### សំរេច

**មាត្រា ១ ._** ត្រូវបានប្រគល់ **មេដាយសេនាសុវត្ថារា** ជូនលោក OKUDAILA Hiroshi ជំនាញការជប៉ុន ប្រចាំក្រសួងធនធានទឹក និងឧតុនិយម ដែលមានស្នាដៃល្អ ក្នុងការជួយអភិវឌ្ឍន៍វិស័យធនធានទឹក នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ១៩៤ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៨៩/អនក្រ/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ ប្រភេទ និងជូនសញ្ញាសជនខ្មែរ នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគថវិកា ជួយកសាងវិស័យសុខាភិបាលនៅខេត្តបាត់ដំបង ដូចមានរាយព្រះនាម និងនាមតាមលំដាប់ថ្នាក់ខាងក្រោម ៖

**ក-មេដាយមាស ស្ថាបនាជាតិ :**

-ព្រះតេជគុណ **អគ្គធិបតី លី ទ័ន និងពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ ថវិកា ១៣.៩៥០ ដុល្លារអាមេរិក**

**ខ-មេដាយ សំរិទ្ធ ស្ថាបនាជាតិ :**

១-ព្រះតេជគុណ សុធម្មោ ជុំ ផុន ថវិកា ២.០០០ ដុល្លារអាមេរិក

២-លោក **ប៊ុន ឡើន ថវិកា ២.០០០ ដុល្លារអាមេរិក**

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ១៥៥ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញអនុក្រឹត្យលេខ ៨៩/អនក្រ/១០៩៥/០១ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា ១ .**_ ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ ជូនលោកស្រី ឆាន គីមច្ចន់ រស់នៅសហរដ្ឋអាមេរិកដែលបានជួយកសាងអាគារសិក្សាមួយខ្នង រួមនឹងសម្ភារៈសិក្សា អណ្តូងទឹក និងបង្គន់អនាម័យ ជូនសាលាបឋមសិក្សាទ្រា ក្នុងឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ចំណាយអស់ទឹកប្រាក់ចំនួន ២២.០០០ ដុល្លារអាមេរិក ។

**មាត្រា ២ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិង កីឡា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩៩

**សេចក្តីសំរេចលេខ ៤១ សសរ**

**ស្តីពីការបង្កើតគណៈកម្មការសំរាប់ដោះស្រាយឈើចំនួន ៣៩១**

**កំណាត់ ស្មើនឹង ១.៥៣៧,៥២៩ម៉³ ដែលតុលាការខេត្តកណ្តាល**

**បានសំរេចអោយលក់ឡាយឡុង**

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- យោងតាមការងារចាំបាច់

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការសំរាប់ដោះស្រាយឈើចំនួន ៣៩១ កំណាត់ ស្មើនឹង ១.៥៣៧,៥២៩ ម³ ដែលតុលាការខេត្តកណ្ដាលបានសំរេចអោយលក់ឡាយឡុង ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ប្រធាន |
| ២-តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣-តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៤-តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥-តំណាងខេត្តកណ្ដាល | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច ៖

-ចុះពិនិត្យជាក់ស្ដែងចំនួនឈើដែលបានរក្សាទុកនៅឃ្លាំងរោងចក្រអារឈើកាសូទីម នៅ ឃុំជីផ្អ ស្រុកកៀនស្វាយ ខេត្តកណ្ដាល

-ពិភាក្សាកំណត់ថ្លៃឈើ និង រៀបចំដាក់អោយដេញថ្លៃតាមបែបបទ និង នីតិវិធីជាធរមាន

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារខាងលើជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អភិបាលខេត្តកណ្ដាល និង ឯកឧត្ដមអស់លោក តំណាងក្រសួង និង ខេត្តដែលមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី

ឧបនាយក

ហត្ថលេខា និងត្រា

**ស ខេង**

★★★

# ៣-សេចក្ដីប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩៩

## សេចក្ដីប្រកាសលេខ ០២ ប្រក.
## ស្ដីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យជលផល

***

ដោយពិនិត្យឃើញថា ទោះបីមានក្រឹត្យច្បាប់លេខ ៣៣ក្រ.ច ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៨៧ ស្ដីពីការគ្រប់គ្រងវិស័យជលផល និងលិខិតបទដ្ឋានជាច្រើនទៀត ដែលរាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់ តាមតំណាក់កាលនីមួយៗ សំដៅមានវិធានការទប់ស្កាត់បទល្មើសជលផលក៏ដោយ ក៏នៅតែមានជនល្មើសបាន និងកំពុងឆ្លៀត ឱកាសប្រព្រឹត្តបទល្មើសជលផល បង្កអោយមានការបំផ្លិចបំផ្លាញប្រភពធនធានជលផលយ៉ាងធ្ងន់ធ្ងរនៅឡើយ ។ ជាក់ស្ដែងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា ភាពអនាធិបតេយ្យលើវិស័យជលផលកំពុងតែគំរាមកំហែងគួរអោយព្រួយបារម្ភ ហើយប្រសិនបើទង្វើល្មើសទាំងនេះនៅតែបន្តទៅទៀតនោះ ប្រទេសកម្ពុជា នឹងឈានទៅបាត់បង់ទាំងបរិមាណ និងប្រភេទពូជត្រី នៅពេលអនាគតខាងមុខ ។

ស្ថិតនៅចំពោះមុខស្ថានភាពខាងលើ រាជរដ្ឋាភិបាលសំរេចកំណត់នូវវិធានការយ៉ាងម៉ឺងម៉ាត់ និងជាបន្ទាន់ដូចខាងក្រោម ៖

១-អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ និងសមត្ថកិច្ចពាក់ព័ន្ធ ត្រូវសហការជាមួយសមត្ថកិច្ចជលផលជាបន្ទាន់ បញ្ឈប់នូវការយកដែននេសាទដែលត្រូវការពារ និងកន្លែងនេសាទដែលទុកសំរាប់តែប្រជារាស្ត្រធ្វើអាជីវកម្មនេសាទ សិប្បកម្ម ឬ គ្រួសារទៅលក់អោយឯកជនដោយខុសច្បាប់ ។

២-ត្រូវបញ្ឈប់ការរាំងទឹកនៅក្នុងដែននេសាទដែលត្រូវការពារ និងក្នុងកន្លែងនេសាទបំរុងទុកនៅបឹងទន្លេសាប និងការធ្វើនេសាទដោយប្រើឧបករណ៍ហាមឃាត់ ជាពិសេសការប្រើជាតិផ្ទុះ ខ្សែភ្លើងឆក់ ការដាក់សំរាស់ ការដាក់កង់ឡាន ឬការធ្វើនេសាទដោយឧបករណ៍នេសាទដែលរុញ ឬអូសដោយកម្លាំងម៉ាស៊ីនជាដើមនៅទឹកសាប ។ ត្រូវហាមឃាត់ដាច់ខាតការផលិត ការលក់ ឬការដឹកជញ្ជូនឧបករណ៍នេសាទហាមឃាត់ ។

៣-ត្រូវបញ្ឈប់ការលើកទំនប់ ការកាប់រានព្រៃលិចទឹក ការផ្ដល់លិខិតសំគាល់សិទ្ធិគ្រប់ប្រភេទលើដីធ្លី ក្នុងដែននេសាទ ដោយគ្មានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៤-ត្រូវបញ្ឈប់ការនេសាទដោយខុសច្បាប់នៅក្នុងរដូវបិទនេសាទ ។
ត្រូវហាមឃាត់ការចាប់កូនត្រី និងជាពិសេសការនាំកូនត្រីចេញទៅបរទេស ។

៥-ត្រូវបញ្ឈប់ការលើករលេខស្នោះអោយទូកនេសាទបរទេសធ្វើអាជីវកម្មនេសាទ និងត្រូវបញ្ឈប់សកម្មភាពនេសាទល្មើសច្បាប់ នៅក្នុងដែនសមុទ្រកម្ពុជា ។

៦-ជនល្មើស និងអ្នកឃុបឃិត ឬអ្នកនៅពីក្រោយខ្នងការពារជនល្មើសក្នុងចំណុច ១.២.៣.៤.៥ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមានដ៏តឹងរឹងបំផុត ។ ឧបករណ៍ សំភារៈ និងមធ្យោបាយផ្សេងៗ ដែលធ្វើនេសាទល្មើសច្បាប់ត្រូវរឹបអូសទុក និងបញ្ជូនទៅតុលាការ ។

៧-ការត្រួតពិនិត្យ ការគ្រាវជ្រាវរកបទល្មើសជលផល ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចជលផល ។ អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវជួយផ្តល់កម្លាំងក្នុងការត្រួតពិនិត្យបទល្មើសជលផល ក្នុងករណីដែលមានការស្នើសុំពីសមត្ថកិច្ចជលផល ។

៨-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ត្រូវពិភាក្សាអំពីឡូត៍នេសាទ ដែលត្រូវរក្សាទុក និងឡូត៍នេសាទដែលត្រូវលុបចេញ ។

៩-សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ ត្រូវចាត់វិធានការម៉ឺងម៉ាត់ និងសមស្របចំពោះកងកម្លាំងប្រដាប់អាវុធទាំងអស់ ដែលពាក់ព័ន្ធនឹងចំណុចបទល្មើសនេសាទទឹកសាប និងសមុទ្រជាបន្ទាន់ និងត្រូវបង្កលក្ខណៈងាយស្រួលដល់សមត្ថកិច្ចជលផលក្នុងការបំពេញភារកិច្ច ។

១០-មន្ត្រីរាជការជលផល សមត្ថកិច្ចផ្សេងៗ និងជនដែលមានស្នាដៃក្នុងការចូលរួមបង្ក្រាបបទល្មើសជលផល ត្រូវបានផ្តល់រង្វាន់លើកទឹកចិត្ត ដែលបានមកពីការផាកពិន័យ ដូចសមត្ថកិច្ច រុក្ខាប្រមាញ់ និងសមត្ថកិច្ចគយដែរ ។

១១-ជនណាអនុវត្តផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។ ទទួលបានសេចក្តីប្រកាសនេះគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ ត្រូវខិតខំអនុវត្តនូវវិធានការខាងលើនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់ អោយមានប្រសិទ្ធភាព ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# III- ការងារបណ្តាក្រសួង

## ១-នីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៩

**ប្រកាសលេខ ៣៦២ ប្រក.សហវ.ពដ**

**ស្តីពីការបង្កើតផ្នែកគ្រប់គ្រង និង ប្រមូលពន្ធតាមរបបពិត**

***

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/ប១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញការចាំបាច់សំរាប់កិច្ចការគ្រប់គ្រងប្រមូលពន្ធ
- តាមសំណើរបស់ប្រធាននាយកដ្ឋានពន្ធដារ

**សំរេច**

ប្រការ ១ : ត្រូវបង្កើតនៅក្នុងសាខាពន្ធដារខេត្ត -ក្រុង ព្រះសីហនុ កោះកុង សៀមរាប បាត់ដំបង និង កំពង់ចាម នូវផ្នែកគ្រប់គ្រង និង ប្រមូលពន្ធចំពោះសហគ្រាសក្រោមគ្រប់ទ្រង់ទ្រាយដែលត្រូវជាប់ពន្ធតាមរបបពិត ហើយដែលមានទីស្នាក់ការជាគោលដើមនៅក្នុងខេត្ត-ក្រុងរបស់ខ្លួន ។

ប្រការ ២ : ផ្នែកគ្រប់គ្រង និង ប្រមូលពន្ធតាមរបបពិត ត្រូវដឹកនាំ និង គ្រប់គ្រងដោយប្រធានម្នាក់ អនុប្រធានម្នាក់ឬពីររូបជាជំនួយការ និង រួមមាន ៣ ក្រុម :

- ក្រុមចុះបញ្ជី
- ក្រុមគណនាពន្ធ
- ក្រុមប្រមូលពន្ធ

**ប្រការ ៣ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និងអង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**គង់ ទិបុល**

★★★

## ២- និស្តិការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩

**ប្រកាសលេខ ៤៥០ ឧក.ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេច នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២២៥៧/៩៨ គ.វ.ត ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិត ៥៧៣ ប.ស្ថ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៩៩ របស់ក្រសួងបរិស្ថាន
- បានឃើញលិខិតលេខ ១០០ ឈអ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៨ របស់សាលាខេត្តកណ្តាល ស្តីពីការអនុញ្ញាតអោយសាងសង់អាគារផលិតស្បែកជើង
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ស្កាយស្តារ ហ្វូតវែរ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៩

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន ស្កាយស្តារ ហ្វូតវែរ ( SKY STAR FOOTWEAR CO, LTD) តំណាងដោយលោកស្រី LIAO YUEH MEI សញ្ជាតិចិន ( តៃវ៉ាន់ ) ភេទស្រី អាយុ ៥៣ ឆ្នាំ អាសយដ្ឋាន # ៣៦៨ Patun Rd. Tai Chung TAIWAN R.O.C កាន់លិខិតឆ្លងដែនលេខ M 11325178 ចុះថ្ងៃទី 25-11-1995 បង្កើត "រោងចក្រផលិតស្បែកជើងនាំចេញ" ដែលមានឈ្មោះថា "រោង

ចក្រកែច្នៃស្បែកជើង ស្តាយស្តារ ហ្វូតវែរ " មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៤ ភូមិព្រៃពពេល ឃុំ ពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ។

ប្រការ ២ : ការសាងសង់និងរៀបចំគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាសមិទ្ធលទ្ធភាព បង្កើតរោងចក្រផលិតស្បែកជើងដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អោយ បានសំរេចក្នុងរយៈពេល ៣ ខែដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាព ផលិតផលហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវ " ស្បែកជើង " ទៅតាមគំរូ ដែលតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវស្នើសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហ-កម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបដ្ឋាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅ ខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសនឹងខ្លឹមសារប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះ ត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និង ប្រធានក្រុមហ៊ុន ស្តាយ ស្តារ ហ្វូតវែរ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស៊ុយ សែម

***

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៩

## ប្រកាសលេខ ៥៧៦ ស្តីពី ផក.ប្រក

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៧៨/៩៩ គ.វ.ត ចុះថ្ងៃទី២៦ ខែកម្ភៈ ឆ្នាំ១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញការឯកភាពលើប្លង់សាងសង់ អគារកាត់ដេររបស់សាលាខេត្តកណ្តាល ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៧
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ខេមបូឌា កណ្តាល ប្រវិនស៍ មេនូហ្វេក ឈឺរីង ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៩៩

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន ខេមបូឌា កណ្តាល ប្រវិនស៍ មេនូហ្វេក ឈឺរីង ( CAMBODIA KANDAL PROVINCE MANUFACTURING LIMITED ) តំណាងដោយលោកស្រី CHEUNG WUN SHEUNG សញ្ជាតិចិន ភេទស្រី អាយុ ៣៩ ឆ្នាំ អាសយដ្ឋាន Flatc C, 3Floor, KK Industrial Building 5 Mok Chong Street Tokwawan , Kowloon, HONG KONG កាន់លិខិតឆ្លងដែនលេខ H 90036322 ចុះថ្ងៃទី 8-01-1998 បង្កើត "រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ " ដែលមានឈ្មោះថា "រោងចក្រកាត់ដេរ ខេមបូឌា កណ្តាល ប្រវិនស៍ " មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ២១ ភូមិកំពង់ព្រីង ឃុំ សិត្បូ ស្រុក ស្អាង ខេត្តកណ្តាល ។

**ប្រការ ២ :** ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាសមិទ្ធលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ ថាមពល ។

**ប្រការ ៣ :** ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផលហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

**ប្រការ ៤ :** រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវ " កាត់ដេរ -សំលៀកបំពាក់ " ទៅតាមគំរូ ដែលតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៥ :** រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៦ :** ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្ដាល និង ប្រធានក្រុមហ៊ុន ខេមបូឌា កណ្ដាល ប្រូវិនស៍ មេនូហ្វេក ឈ័ររីង ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស៊ុយ សែម

★★★